

# សហគមន៍នៅ Springvale ទទួលបាន មូលនិធិលើកកំពស់វប្បធម៌

វប្បធម៌ដ៏រឹងមាំនៅតំបន់ Springvale ដែលផ្សារភ្ជាប់នឹងសហគមន៍ជនជាតិចិន វៀតណាម និងខ្មែរនឹងត្រូវបានពង្រឹងបន្ថែមទៀតតាមរយៈការសង់ក្លោងទ្វារថ្មីមួយ ព្រមជាមួយនឹងការពង្រីកទីផ្លាសហគមន៍។

លោក James Merlino រដ្ឋមន្ត្រីជំនួយការរដ្ឋមន្ត្រីទី១លើកិច្ចការពហុវប្បធម៌បានមានប្រសាសន៍ថា សមាគមធុរកិច្ចអាស៊ីស្ព្រីងវែល (Springvale Asian Business Association) និងសមាគមនខ្មែរវិចតូរីយ៉ា ទទួលបានមូលនិធិចំនួន ២៥០,០០០ដុល្លារ ពីរដ្ឋាភិបាលគណៈបក្សពលកររបស់លោក John Brumby សម្រាប់តំបន់ Springvale ។

រដ្ឋវិចតូរីយ៉ាមានមោទនភាពជាមួយនឹងមត៌កវប្បធម៌របស់យើង ។ យើងទាំងអស់គ្នាមានដើមកំណើតមកពីប្រទេសជាង២០០ និយាយភាសាជាង២០០ និងគោរពជំនឿសាសនាជាង១១០ ។ យើងទាំងអស់គ្នាកំពុងធ្វើការជាមួយសហគមន៍ អង្គការនិងក្រុមប្រឹក្សាដើម្បីថៃរក្សាមត៌កវប្បធម៌របស់យើងតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងតំបន់វប្បធម៌ដោយការប្រើប្រាស់មូលនិធិតំបន់វប្បធម៌និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដែលមានទឹកប្រាក់ ១០លានដុល្លារ ។

លោកបានបន្ថែមទៀតថា " មូលនិធិនេះនឹងជួយបង្កើតនូវសារៈប្រយោជន៍ដ៏សំខាន់សម្រាប់សហគមន៍អាស៊ីនៅតំបន់ Springvale ដែលជាតំបន់បេះដូងសង្គមរបស់សហគមន៍ជនជាតិចិន វៀតណាម និងខ្មែរ។"

លោក Merlino មានប្រសាសន៍បន្តទៀតថា ថវិកាត្រឹម១៧៥,០០០ដុល្លារ នឹងផ្តល់ទៅឲ្យសមាគមធុរកិច្ចអាស៊ីស្ព្រីងវែលសម្រាប់ការសង់ក្លោងទ្វារអាស៊ីនៅមជ្ឈមណ្ឌលលក់ដូរ Springvale លើចំនុចប្រសព្វរវាងផ្លូវ Buckingham និងផ្លូវ Windsor ។ ហើយទឹកប្រាក់ចំនួន ៨០,០០០ដុល្លារ បន្ថែមទៀតនឹងផ្តល់ទៅឲ្យសមាគមខ្មែរវិចតូរីយ៉ាសម្រាប់ពង្រីកទីផ្លាសហគមន៍ ដែលមានទីតាំងនៅលេខ 52 Queens Street, Springvale ។

លោក ហុង លីម សមាជិកសភាតំបន់ខ្មែយតុនបានមានប្រសាសន៍ថា មូលនិធិនេះគឺជាមូលនិធិបន្ថែមរបស់មូលនិធិតំបន់វប្បធម៌និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដែលបានអនុវត្តប្រកបដោយជោគជ័យរួចមកហើយនៅតំបន់វប្បធម៌កណ្តាលក្រុងមែលប៊ិនរបស់សហគមន៍ជនជាតិក្រិក អ៊ីតាលី និងចិន។

លោក ហុង លីម មានប្រសាសន៍បន្តទៀតថា សហគមន៍អាស៊ីរបស់យើងបន្តដើរតួនាទីយ៉ាងសកម្មក្នុងការបន្តថែរក្សាកិត្តិនាមរបស់យើងក្នុងនាមជាសង្គមចម្រុះដែលពោរពេញទៅដោយមត៌កវប្បធម៌ និងសាសនាដ៏សម្បូរបែប។